**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាបើកការអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់**
**ភ្នំពេញថ្មី ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០**
**ចូរយើងអធិដ្ឋាន**

**អត្ថបទទី១៖ មីកា ៧,១៤-១៥.១៨.២០**

បពិត្រព្រះអម្ចាស់! តើមានព្រះណា ដែលមានព្រះហឫទ័យសប្បុរសដូចព្រះអង្គ? ព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំ ព្រះអង្គមិនពិរោធរហូតឡើយ។ ព្រះអង្គមានព្រះហឫទ័យស្រឡាញ់ ប្រជារាស្ត្ររបស់ព្រះអង្គដែលនៅសេសសល់ ហើយព្រះអង្គប្រណីសន្ដោសដល់ពួកគេ។ មីក ៧,១៨

**ដំណឹងល្អ៖ លូកា ១៥,១-៣.១១-៣២**

អញត្រូវតែវិលត្រឡប់ទៅរកឪពុកអញវិញ ហើយជម្រាបគាត់ថា លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ។ លក ១៥,១៨

បងប្អូនជាទីស្រឡាញ់!

នៅពេលយើងបើកការអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ យើងបានស្ដាប់ព្រះបន្ទូលពីរ នៅក្នុងអត្ថបទទីមួយ "**ឱព្រះអម្ចាស់អើយ! សូមថែរក្សាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ ដូចគង្វាលធ្លាប់ថែរក្សាហ្វូងសត្វរបស់ខ្លួន សូមនាំយើងខ្ញុំទៅរស់នៅកន្លែងដែលមានជីជាតិដ៏ល្អប្រសើបំផុត ព្រះអង្គនឹងសម្ដែងព្រះហឫទ័យស្មោះស្ម័គ្រដល់កូនចៅរបស់លោកយ៉ាកុប**"។ នៅពេលយើងស្ដាប់ព្រះបន្ទូលនេះ យើងនឹកឃើញរបៀបដែលព្រះជាម្ចាស់ថែរក្សានិងស្រឡាញ់យើង របៀបដែលព្រះជាម្ចាស់មានព្រះហឫទ័យស្មោះស្ម័គ្រដល់យើង របៀបដែលព្រះជាម្ចាស់ធ្វើដំណើរជាមួយយើង ដើម្បីឲ្យយើងចេញពីកន្លែងដែលក្រៀមស្ងួតចូលនៅវាលស្រែខៀវខ្ចី។ ព្រះជាម្ចាស់យកអំពើបាបរបស់មនុស្សបោះចោលនៅក្នុងសមុទ្រយ៉ាងជ្រៅ ២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ខ្ញុំបានណែនាំឲ្យយើងទាំងអស់នៅក្នុងភូមិភាគភ្នំពេញអធិដ្ឋានសម្រាប់៖

-ការត្រាស់ហៅ យើងចូលនៅក្នុងយប់ទី៩១ដែលយើងអធិដ្ឋានជាប្រចាំខែដែលយើងមាន

-បងប្អូន និងប្រទេសដែលជំងឺកូវីដ១៩បានវាយលុក សម្រាប់បងប្អូនដែលឈឺ សម្រាប់បងប្អូនដែលភ័យ សម្រាប់បងប្អូនដែលកំពុងព្យាបាល និងសម្រាប់មនុស្សមួយចំនួនដែលកំពុងយកចិត្តទុកដាក់រកថ្នាំបង្ការនិងព្យាបាលជំងឺនេះ និងសម្រាប់សេដ្ឋកិច្ចពិភពលោក

-សុខសន្តិភាពនៅក្នុងពិភពលោក

-សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ

-លោកអភិបាល

-សម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា ជាពិសេសសម្រាប់បងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកនៅរាត្រីបុណ្យចម្លងខាងមុខនេះ

-បងប្អូនម្នាក់ៗ ដែលមានការអធិដ្ឋានផ្ទាល់ខ្លួនផ្ញើទៅព្រះជាម្ចាស់។

ពេលយើងមើល៧ចំណុចខាងលើនេះ **តើមានចំណុចមួយដែលណែនាំឲ្យ៧ចំណុចនេះរកឃើញអត្ថន័យដ៏ពិសេសឬទេ?** អត្ថន័យដ៏ពិសេសយើងអាចរកឃើញនៅក្នុងអត្ថបទទី១ និងនៅក្នុងព្រះគម្ពីរដំណឹងល្អគឺ "**ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះស្ម័គ្រ ព្រះជាម្ចាស់មានភក្តីភាពសម្រាប់យើងទាំងអស់គ្នា**"។ ដូចពីដើម សម្រាប់លោកយ៉ាកុប សម្រាប់លោកតាអប្រាហាំ សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គព្រះជាម្ចាស់មានព្រះហឫទ័យស្មោះស្ម័គ្រ។ យើងឃើញនៅក្នុងគម្ពីរដំណឹងល្អ ព្រះយេស៊ូបង្ហាញអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលជាព្រះបិតា សម្រាប់កូនពៅវង្វេងក្តី សម្រាប់កូនច្បងក្តីដែលកំពុងមានចិត្តច្រណែន ប៉ុន្តែព្រះបិតាបានខិតខំអប់រំណែនាំគាត់ឲ្យភ្ញាក់ស្មារតី។ ព្រះជាម្ចាស់ មានព្រះហឫទ័យស្មោះស្ម័គ្រសម្រាប់យើងទាំងអស់គ្នា នេះជាមូលដ្ឋានគ្រឹះនៃជំនឿរបស់យើង ដោយដឹងថាមិនមែនតែយើងដែលខិតខំមានចិត្តស្មោះចំពោះព្រះជាម្ចាស់ ប៉ុន្តែមុនគេបង្អស់មានតែព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ អត់ដែលលះបង់ចោលយើងអស់កល្បជានិច្ច។

ដូច្នេះ ពេលយើងមើលចំណុចនីមួយៗដែលខ្ញុំជូនឲ្យបងប្អូនសម្រាប់អធិដ្ឋាន២៤ម៉ោងនេះ យើងរកឃើញរបៀបដែលព្រះជាម្ចាស់ឆ្លើយតបពីមួយថ្ងៃទៅមួយថ្ងៃ ដល់ពាក្យទូលអង្វររបស់យើង។ ប្រសិនបើ យើងមើល៩១យប់ដែលយើងបានអធិដ្ឋានសម្រាប់ការត្រាស់ហៅពីប៉ុន្មានឆ្នាំកន្លងមក យើងមានការត្រាស់ហៅខ្លះទាំងនៅទេវវិទ្យាល័យ ទាំងនៅកន្លែងបងស្រីមួយចំនួន យើងមានយុវជនខ្លះមានយុវនារីខ្លះនៅក្នុងក្រុមអេម៉ានូអែល ក្រុមសាមូ៉អែល រៀងៗខ្លួនទោះបីមិនបានចូលក្នុងក្រុមណាមួយក៏កំពុងគិតពិចារណា អំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ដែរ។ នេះជារបៀប ដែលព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ចំពោះយើងនៅប្រទេសកម្ពុជា ដោយយើងដឹងថាព្រះអង្គមិនលះបង់ចោលយើងទេ ដើម្បីឲ្យព្រះសហគមន៍យើងមានអ្នកបម្រើដ៏ស្មោះស្ម័គ្រ ដើម្បីបម្រើព្រះសហគមន៍តទៅទៀត។

ប្រសិនបើយើងមើលសេចក្តីសុខសាន្ត និងសន្តិភាពនៅក្នុងពិភពលោក មានតែការអធិដ្ឋានរបស់យើងដែលអាចបើកទ្វារដ៏តូចមួយនៅក្នុងបេះដូងរបស់យើងផ្ទាល់ខ្លួន ដើម្បីនឹកឃើញពិតមែនព្រះជាម្ចាស់ស្រឡាញ់យើងកម្រិតណា ពិតមែនព្រះជាម្ចាស់ណែនាំឲ្យយើងមានសេចក្តីសង្ឃឹមកម្រិតណា។ ពេលយើងនឹកឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង ពេលយើងនឹកឃើញព្រះហឫទ័យស្មោះស្ម័គ្ររបស់ព្រះជាម្ចាស់ចំពោះយើង ណែនាំឲ្យយើងភ្ញាក់ស្មារតីដែរ។ ដោយដឹងថា ខ្ញុំជាមនុស្សតូចតាចមែនតែខ្ញុំធ្វើដូចម្តេចដើម្បីចូលរួមកសាងសុខសន្តិភាពនៅក្នុងពិភពលោក ខ្ញុំធ្វើដូចម្តេចដើម្បីឆ្លើយតបដល់សេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះខ្ញុំ ដោយខិតខំយកចិត្តទុកដាក់កែប្រែចិត្តគំនិតថែមទៀត ដើម្បីឲ្យពិភពរបស់ខ្ញុំ ឲ្យសង្គមរបស់ខ្ញុំ ឲ្យព្រះសហគមន៍របស់ខ្ញុំ ឲ្យគ្រួសាររបស់ខ្ញុំ ឲ្យខ្ញុំផ្ទាល់ខ្លួន អាចរកឃើញសេចក្តីសុខនៅក្នុងចិត្ត។

ពេលយើងនឹកឃើញដល់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ យើងដឹងថាតួនាទីជាសម្តេចប៉ាបធ្ងន់ណាស់ដើម្បីដឹកនាំព្រះសហគមន៍ទូទាំងពិភពលោក។ ត្រូវការប្រឈមមុខនឹងបញ្ហានានានៅក្នុងសង្គមបច្ចុប្បន្ននេះ នៅក្នុងពិភពលោកផង នៅក្នុងព្រះសហគមន៍ផង នៅក្នុងការដឹកនាំបុរីវ៉ាទីកង់ផង ដែលត្រូវការមានកម្លាំងណាស់។ យើងដឹងថា សម្តេចប៉ាបមានសសរមួយដ៏រឹងមាំគឺព្រះហឫទ័យស្រឡាញ់ ព្រះហឫទ័យស្មោះត្រង់របស់ព្រះជាម្ចាស់ចំពោះសម្តេចប៉ាប ដើម្បីមានកម្លាំងណែនាំព្រះសហគមន៍យើងតទៅទៀត។

សម្រាប់ខ្ញុំផ្ទាល់ក៏ដូចគ្នាដែរ ១០ឆ្នាំជាអភិបាល មានខ្លះគិតថាស្រួលណាស់ យើងមានទាំងទុក្ខលំបាក ទាំងអំណរសប្បាយ ទាំងការតស៊ូ ទាំងការធ្លាក់ទឹកចិត្ត នេះណែនាំឲ្យខ្ញុំនឹកឃើញគ្រប់ពេលវេលា ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំព្រះអង្គបានប្រទានកម្លាំងដល់ខ្ញុំដើម្បីទៅមុខបាន។ ខ្ញុំរកឃើញកម្លាំងតាមរយៈព្រះជាម្ចាស់ផង និងតាមរយៈបងប្អូនទាំងអស់ផង ដូចជាខ្ញុំពិសោធអំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ អំពីរបៀបដែលព្រះជាម្ចាស់ថែរក្សាខ្ញុំ អំពីរបៀបដែលព្រះជាម្ចាស់ណែនាំឲ្យខ្ញុំយកចិត្តទុកដាក់ថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គ។ យើងជាគ្រូគង្វាលដែលត្រូវតែថែរក្សាហ្វូងសត្វរបស់ខ្លួន តាមសមត្ថភាពផ្ទាល់ខ្លួននិងតាមកម្លាំងដែលយើងបានទទួលពីព្រះជាម្ចាស់ និងពីបងប្អូននៅក្នុងព្រះសហគមន៍យើងដែរ។

ពេលយើងនឹកឃើញដល់ព្រះសហគមន៍របស់យើងនៅក្នុងភូមិភាគភ្នំពេញ ឆ្នាំនេះយើងគោរព៣០ឆ្នាំដែលព្រះសហគមន៍របស់យើងបានកើតសាជាថ្មី។ សកម្មភាពព្រះសហគមន៍ក្នុងសម័យប៉ុលពត និងក្រោយសម័យនោះបន្តិចដូចជាជិតសូន្យម្យ៉ាងដែរ។ នៅក្នុង៣០ឆ្នាំកន្លងមកយើងបានមើលឃើញរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង ព្រះជាម្ចាស់បានផ្តល់សាសនទូតបងប្រុសបងស្រី និងក្រុមនានាមកព្រះសហគមន៍នៅប្រទេសកម្ពុជា ណែនាំឲ្យព្រះសហគមន៍

របស់យើងមានជីវិតបន្តិចម្តងៗសាជាថ្មី។ ជាពិសេស ព្រះជាម្ចាស់បានណែនាំឲ្យយើងមានគ្រីស្តបរិស័ទកម្ពុជា ដែលយកចិត្តទុកដាក់ទទួលខុសត្រូវយ៉ាងខ្ពស់នៅក្នុងព្រះសហគមន៍។ នៅក្នុង៣០ឆ្នាំ យើងមានបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹកជាង៣០០០នាក់ នៅក្នុងភូមិភាគភ្នំពេញដើម្បីបង្កើតព្រះសហគមន៍តាមកន្លែងនានា។ សព្វថ្ងៃ យើងមាន៥០កន្លែងដែលមានគ្រីស្តបរិស័ទជាវត្តមានរបស់ព្រះយេស៊ូ ជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះត្រង់ចំពោះប្រជារាស្ត្រកម្ពុជាយើង។

ពេលយើងនឹកឃើញដល់មេរោគកូវីណា ណែនាំឲ្យបងប្អូនទូទាំងពិភពលោកភ័យខ្លាច និងមានការសង្ស័យច្រើន។ ពេលយើងឃើញប្រទេសមួយចំនួននៅក្នុងពិភពលោក ដែលកំពុងបិទទ្វារប្រទេស បិទសាលា បិទការជួបជុំគ្នា... ណែនាំឲ្យយើងភ័យខ្លាច។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងត្រូវការនឹកឃើញអំពីកម្លាំងដែលយើងបានទទួលពីព្រះជាម្ចាស់ ដើម្បីឲ្យយើងមានសេចក្តីក្លាហាន ដើម្បីឲ្យជំនឿរបស់យើងរីកចម្រើនថែមទៀត។ ពេលវេលាដែលយើងរស់នៅក្នុងពិភពលោកសព្វថ្ងៃ ដូចជារដូវត្រណមមួយយ៉ាងវែងណាស់ដែលមនុស្សយើងមិនចង់មាន។ យើងមិនចង់ចូលនៅក្នុងវាលរហោស្ថាន៤០ថ្ងៃ យើងមិនចង់តមអាហារ និងរស់នៅរៀងៗខ្លួន៤០ថ្ងៃដូចព្រះយេស៊ូពីដើម។ ប៉ុន្តែឥឡូវនេះនៅក្នុងពិភពលោក ទាំងគ្រីស្តបរិស័ទ ទាំងមិនមែនជាគ្រីស្តបរិស័ទ ដូចជាយើងចូលនៅក្នុងរដូវ៤០ថ្ងៃយ៉ាងពិសេសណែនាំឲ្យយើងនៅតែផ្ទះយើង ណែនាំឲ្យយើងថែរក្សាសុខភាពយើងផ្ទាល់។ យើងទទួលខុសត្រូវលើយើងផ្ទាល់ និងយើងទទួលខុសត្រូវលើបងប្អូនឯទៀតៗដែរ វាជាពេលវេលាមួយដើម្បីឲ្យយើងនឹកឃើញតម្លៃនៃជីវិតរបស់យើង ដើម្បីឲ្យយើងនឹកឃើញអ្វីដែលសំខាន់សម្រាប់ជីវិតរបស់យើងផ្ទាល់។ ពេលយើងលែងទៅដើរលេងបាន ពេលយើងលែងទៅកន្លែងដែលយើងចង់ទៅបាន ពេលយើងលែងទៅព្រះវិហារបាន... នៅពេលនោះយើងដូចជានៅម្នាក់ឯងក្នុងបន្ទប់ ជាពេលវេលាដើម្បីគិត **តើអ្វីដែលសំខាន់នៅក្នុងជីវិតខ្ញុំ?** សម្រាប់យើងជាគ្រីស្តបរិស័ទ យើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាទីពឹងពិសេស ដែលណែនាំឲ្យជីវិតរបស់យើងរកឃើញតម្លៃនៃជីវិត។ ជាពិសេស ឲ្យយើងសម្លឹងមើលរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង នៅពេលព្រះយេស៊ូសោយទិវង្គតលើឈើឆ្កាង ព្រះយេស៊ូបានណែនាំឲ្យយើងចូលនៅក្នុងជីវិតថ្មីរបស់ព្រះអង្គ និងណែនាំឲ្យយើងមើលឃើញយ៉ាងជាក់ស្តែងព្រះហឫទ័យស្មោះត្រង់របស់ព្រះជាម្ចាស់ចំពោះយើងរៀងៗខ្លួន។

នៅក្នុង២៤ម៉ោងនេះ ឲ្យយើងទាំងអស់គ្នាជឿលើព្រះជាម្ចាស់ដែលមានការអស្ចារ្យសម្រាប់យើង។ នៅក្នុងអត្ថបទទី១ "**សូមសម្តែងព្រះបារមីដ៏រុងរឿងអស្ចារ្យ ដូចកាលព្រះអង្គនាំយើងខ្ញុំចេញពីស្រុកអេហ្ស៊ីប**" ខ្ញុំចង់ឲ្យបងប្អូនទាំងអស់ក្នុង២៤ម៉ោងនេះ យើងបើកភ្នែកដើម្បីមើល

ឃើញព្រះបារមីដ៏រុងរឿងអស្ចារ្យរបស់ព្រះអង្គ ដែលណែនាំឲ្យជីវិតរបស់យើងរកឃើញតម្លៃ រកឃើញអត្ថន័យ រកឃើញគោលដៅ ដើម្បីថែរក្សាសេចក្តីសង្ឃឹមរបស់យើង។ សូមព្រះជាម្ចាស់ប្រទានពរ និងថែរក្សាមណ្ឌលសកម្មភាពរបស់យើងទាំង៩ មានមណ្ឌលសកម្មភាពភ្នំពេញថ្មី មណ្ឌលសកម្មភាពភ្នំពេញខាងជើង មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង មណ្ឌលសកម្មភាពមេគង្គ មណ្ឌលសកម្មភាពបាសាក់ មណ្ឌលសកម្មភាពតាខ្មៅ មណ្ឌលសកម្មភាពតាកែវ មណ្ឌលសកម្មភាពកំពត មណ្ឌលសកម្មភាពកំពង់សោម សូមព្រះជាម្ចាស់ណែនាំយើងឲ្យរកឃើញសេចក្តីសង្ឃឹមជានិច្ច ឲ្យយើងរកឃើញសេចក្តីសុខសាន្តនៅក្នុងដួងចិត្តរបស់យើង និងជាពិសេសសូមព្រះជាម្ចាស់ដកចេញអំពើបាបពីដួងចិត្តរបស់យើង បោះចោលនៅក្នុងសមុទ្រយ៉ាងជ្រៅ ដើម្បីឲ្យយើងទាំងអស់មានចិត្តស្រឡាញ់ ចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ និងរកឃើញព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅក្នុងជីវិតរបស់យើងផ្ទាល់ខ្លួន។ អាម៉ែន៕